# ការបង្រៀនជួយសង្គ្រោះដល់ជីវិត

រ៉ូសែល ធី អូសហ្គូសុធប
ប្រធានសាលាថ្ងៃអាទិត្យទូទៅ

*យើងបង្រៀនគោលលទ្ធិសំខាន់ ដោយអញ្ជើញពួកអ្នករៀនឱ្យធ្វើកិច្ចការដែលព្រះមានសំរាប់ពួកគេ រួចហើយសន្យាថាពរជ័យទាំងឡាយនឹងកើតមានយ៉ាងពិតប្រាកដ ។*

ថ្ងៃមួយ នៅពេលកំពុងបំរើជាប្រធានបេសកកម្ម ខ្ញុំនិយាយទូរស័ព្ទទៅកាន់កូនប្រុសច្បងរបស់យើង ។ គាត់កំពុងធ្វើដំណើរទៅកាន់មន្ទីរពេទ្យ ជាកន្លែងដែលគាត់ធ្វើការជាគ្រូពេទ្យ ។ នៅពេលគាត់បានទៅដល់មន្ទីរពេទ្យ គាត់បាននិយាយថា "រីករាយណាស់ដែលបាននិយាយជាមួយប៉ា ប៉ុន្តែឥឡូវខ្ញុំត្រូវចុះពីឡានដើម្បីទៅជួយសង្គ្រោះ ជីវិតមួយចំនួនសិនហើយ" ។

កូនប្រុសរបស់យើងព្យាបាលដល់កុមារតូចៗដែលមានជម្ងឺគ្រោះថ្នាក់ដល់ជីវិត ។ នៅពេលគាត់អាចធ្វើការវិនិច្ឆ័យរោគបានត្រឹមត្រូវ ហើយផ្តល់ការព្យាបាលត្រូវ នោះគាត់អាចជួយជីវិតរបស់កុមារម្នាក់ ។ ខ្ញុំបានប្រាប់ដល់អ្នកផ្សព្វផ្សាយ សាសនារបស់យើងថា កិច្ចការរបស់ពួកគេគឺដើម្បីជួយសង្គ្រោះជីវិតផងដែរ--- ជីវិតខាងវិញ្ញាណរបស់អ្នកទាំងឡាយ ដែលពួកគេបង្រៀន ។

ប្រធាន យ៉ូសែប អេហ្វ ស៊្មីធ បានមានប្រសាសន៍ថា : "នៅពេល[យើងទទួល]សេចក្តីពិត [យើង]នឹងត្រូវបានសង្គ្រោះដោយសារសេចក្តីពិតនោះ ។ [យើង]នឹងមិនត្រូវបានសង្គ្រោះ ដោយគ្រាន់តែមាននរណាម្នាក់បានបង្រៀនការណ៍នោះមកដល់[យើង]ឡើយ ប៉ុន្តែដោយសារ[យើង]បានទទួល និងអនុវត្តតាមការបង្រៀននោះវិញ" ។ (នៅក្នុង Conference Report ខែ មេសា ឆ្នាំ 1902 ទំព័រ 86 សូមមើល *Teaching, No Greater Call* [ឆ្នាំ 1999] ទំព័រ 49; ធីម៉ូថេទី 1 4:16) ។

កូនប្រុសរបស់យើងជួយសង្គ្រោះជីវិត តាមរយៈការចែកចាយចំណេះដឹងរបស់គាត់ខាងវិជ្ជាពេទ្យ ពួកអ្នកផ្សព្វផ្សាយសាសនា និងពួកគ្រូបង្រៀននៅក្នុងសាសនាចក្រជួយសង្គ្រោះជីវិតតាមរយៈការចែកចាយចំណេះដឹងរបស់ពួកគេអំពីដំណឹងល្អ ។ នៅពេលពួកអ្នកផ្សព្វផ្សាយសាសនា និងគ្រូបង្រៀនស្វែងរកដើម្បីទទួលព្រះវិញ្ញាណ នោះពួកគេបង្រៀនគោលការណ៍ត្រឹមត្រូវ អញ្ជើញឱ្យអ្នករៀនរបស់ពួកគេរស់នៅតាមគោលការណ៍នោះ ហើយធ្វើជាសាក្សីនៃពរជ័យដែលបានសន្យាទាំងឡាយថានឹងមកដល់យ៉ាងពិតប្រាកដ ។ អែលឌើរដេវីឌ អេ បែដណា បានចែកចាយនូវធាតុដ៏សាមញ្ញចំនួនបី ដើម្បីបង្រៀនឱ្យមានប្រសិទ្ធភាពនៅក្នុងការប្រជុំបំពាក់បំប៉ននាពេលថ្មីៗនេះថា: (1) គោលលទ្ធិសំខាន់ (2) ការអញ្ជើញឱ្យធ្វើសកម្មភាព និង (3) ពរជ័យដែលបានសន្យា ។

សៀវភៅណែនាំ *ប្រកាសដំណឹងល្អរបស់យើង* ជួយដល់អ្នកផ្សព្វផ្សាយសាសនា បង្រៀនគោលលទ្ធិសំខាន់ អញ្ជើញអ្នកទាំងឡាយដែលពួកគេបង្រៀនឱ្យធ្វើសកម្មភាព ហើយទទួលពរជ័យដែលបានសន្យា ។ សៀវភៅណែនាំ *Teaching, No Greater Call* ជួយដល់ឪពុកម្តាយ និងគ្រូបង្រៀនឱ្យធ្វើដូចគ្នា ។ វាគឺជាការបង្រៀនដំណឹងល្អនូវអ្វី ដែលសៀវភៅ *ប្រកាសដំណឹងល្អរបស់យើង* មានសំរាប់កិច្ចការអ្នកផ្សព្វផ្សាយសាសនា ។ យើងប្រើប្រាស់សៀវភៅទាំងនោះ ដើម្បីរៀបចំការបង្រៀន ហើយយើងស្វែងរកជំនួយពីព្រះវិញ្ញាណ នៅពេលយើងបង្រៀន ។

ប្រធាន ថូម៉ាស អេស ម៉នសុន ប្រាប់អំពីគ្រូបង្រៀនសាលាថ្ងៃអាទិត្យម្នាក់ កាលពីគាត់នៅក្មេង ឈ្មោះ លូស៊ី ហ្គឺតឆ៍។ នៅថ្ងៃអាទិត្យមួយ ពេលបង្រៀនមេរៀនអំពីការបំរើដោយមិនគិតពីខ្លួនឯងបានពាក់កណ្ដាល ស៊ិសស្ទើរ ហ្គឺតឆ៍ បានអញ្ជើញសិស្សរបស់គាត់ឱ្យផ្ដល់ប្រាក់សំរាប់ពិធីជប់លៀងរបស់ពួកគេទៅដល់គ្រួសាររបស់មិត្តក្នុងថ្នាក់ម្នាក់របស់ពួកគេ ដែលម្ដាយបានទទួលមរណភាព។ ប្រធាន ម៉នសុន បានមានប្រសាសន៍ថា នៅពេលផ្ដល់ការអញ្ជើញឱ្យធ្វើសកម្មភាពនោះ ស៊ិសស្ទើរ ហ្គឺតឆ៍ បាន "បិទសៀវភៅ ហើយបើកភ្នែក និងត្រចៀក និងដួងចិត្តរបស់យើងឱ្យមើលឃើញសិរីល្អរបស់ព្រះ" ("Examples of Great Teachers" [ការប្រជុំបំពាក់បំប៉នភាពជាអ្នកដឹកនាំទូទាំងពិភពលោកថ្ងៃទី 10 ខែ កុម្ភៈ ឆ្នាំ 2007] *Liahona* ខែ មិថុនា ឆ្នាំ 2007 ទំព័រ 76)។ ស៊ិសស្ទើរ ហ្គឺតឆ៍ បានប្រើប្រាស់សៀវភៅសិក្សា ដើម្បីរៀបចំមេរៀនរបស់គាត់យ៉ាងច្បាស់លាស់ ប៉ុន្តែនៅពេលមាន ការបំផុសគំនិតមកដល់ គាត់បានបិទសៀវភៅ ហើយបានអញ្ជើញសិស្សរបស់គាត់ ឱ្យរស់នៅតាមគោលការណ៍ដំណឹងល្អ ដែលគាត់កំពុងតែបង្រៀន។

ដូចដែលប្រធាន ម៉នសុន បានបង្រៀន "គោលដៅនៃការបង្រៀនដំណឹងល្អ... គឺមិនមែន 'ចាក់ស្រោចព័ត៌មាន' ទៅក្នុងគំនិតរបស់សមាជិកក្នុងថ្នាក់ទេ...។ គោលបំណងគឺដើម្បីបំផុសគំនិតបុគ្គលម្នាក់ៗឱ្យគិត ឱ្យទទួលអារម្មណ៍ ហើយបន្ទាប់មកធ្វើអ្វីមួយដើម្បីរស់នៅតាម*គោលការណ៍*នៃដំណឹងល្អ" (នៅក្នុង Conference Report ខែ តុលា ឆ្នាំ 1970 ទំព័រ 107)។

នៅពេលម៉ូរ៉ូណៃ បានលេចមកឯព្យាការីយ៉ូសែប មិនគ្រាន់តែបានបង្រៀនដល់លោក អំពីគោលលទ្ធិសំខាន់ នៃការស្ដារឡើងវិញប៉ុណ្ណោះទេ តែម៉ូរ៉ូណៃក៏បានប្រាប់លោកថា "ព្រះមានកិច្ចការមួយសំរាប់[លោក]ធ្វើ"ផងដែរ ហើយបានសន្យានឹងលោកថា ឈ្មោះរបស់លោកនឹងត្រូវបានគេស្គាល់ នៅទូទាំងពិភពលោក (សូមមើល យ៉ូសែប ស្ម៊ីធ---ប្រវត្តិ 1:33)។ ឪពុកម្ដាយ និងគ្រូបង្រៀនដំណឹងល្អទាំងអស់គឺជាសារទូតមកពីព្រះ។ មិនមែនយើងគ្រប់គ្នាបង្រៀនដល់អ្នកដែលនឹងក្លាយជាព្យាការីនាពេលអនាគត ដូចជាស៊ិស្ទើរហ្គឺតឆ៍ និងម៉ូរ៉ូណៃនោះទេ តែយើងទាំងអស់គ្នាកំពុងតែបង្រៀនដល់អ្នកដែលនឹងក្លាយជាពួកអ្នកដឹកនាំសាសនាចក្រនាពេលអនាគត។ ដូច្នេះយើងបង្រៀនគោលលទ្ធិ សំខាន់ អញ្ជើញពួកអ្នករៀនឱ្យធ្វើកិច្ចការដែលព្រះមានសំរាប់ពួកគេ រួចហើយសន្យាថាពរជ័យទាំងឡាយនឹងមានមកដល់យ៉ាងពិតប្រាកដ។

ខ្ញុំចងចាំថា កាលពីនៅក្មេងគ្មានគិតបារម្ភអ្វីទេ នៅពេលខ្ញុំដើរមកព្រះវិហារដើម្បីចូលរួមការប្រជុំថ្នាក់កុមារ។ នៅពេលខ្ញុំបានទៅដល់ ខ្ញុំមានការភ្ញាក់ផ្អើល ដែលបានឃើញឪពុកម្ដាយទាំងអស់នៅទីនោះ សំរាប់កម្មវិធីពិសេស។ ខ្ញុំបានដឹងភ្លាមមួយរំពេច។ ខ្ញុំមានចំណែកនៅក្នុងកម្មវិធីនេះ ហើយខ្ញុំបានភ្លេចទន្ទេញឱ្យចាំវគ្គរបស់ខ្ញុំ។ នៅពេលដល់វេនដែលខ្ញុំត្រូវនិយាយផ្នែករបស់ខ្ញុំ ខ្ញុំបានក្រោកឈរនៅលើកៅអី ប៉ុន្តែអត់និយាយអ្វីសោះ។ ខ្ញុំមិនចាំអ្វីទាំងអស់។ ដូច្នេះខ្ញុំគ្រាន់តែឈរនៅទីនោះ ហើយទីបំផុតអង្គុយចុះ រួចឱនមុខសំឡឹងមើលទៅលើឥដ្ឋ។

បន្ទាប់ពីបទពិសោធន៍នោះ ខ្ញុំបានតាំងចិត្តដ៏មុតមាំមួយថា ខ្ញុំនឹងមិននិយាយនៅក្នុងការប្រជុំណាមួយរបស់សាសនាចក្រម្ដងទៀតទេ។ ហើយខ្ញុំនៅតែធ្វើការតាំងចិត្តនោះអស់មួយរយៈ។ បន្ទាប់មកនៅថ្ងៃអាទិត្យមួយនោះ ស៊ិសស្ទើរ លីឌា ស្ទិលមិន ជាអ្នកដឹកនាំថ្នាក់កុមារ បានលុតជង្គង់ចុះនៅជិតខ្ញុំ ហើយសុំឱ្យខ្ញុំឡើងនិយាយខ្លីៗនៅសប្ដាហ៍ក្រោយ។ ខ្ញុំនិយាយថា "ខ្ញុំមិននិយាយទេ"។ គាត់

បានឆ្លើយថា "គ្រូដឹង ប៉ុន្តែកូនអាចឡើងនិយាយមួយនេះបាន ដោយសារគ្រូនឹងជួយដល់កូន"។ ខ្ញុំនៅតែចចេស ប៉ុន្តែគាត់បានបង្ហាញនូវទំនុកចិត្តយ៉ាងខ្លាំងមកលើខ្ញុំ ធ្វើឱ្យខ្ញុំពិបាកនឹងបដិសេធការអញ្ជើញរបស់គាត់។ ខ្ញុំបានឡើងនិយាយ។

ស្ត្រីល្អម្នាក់នោះ គឺជាសារទូតម្នាក់មកពីព្រះ ដែលមានកិច្ចការមួយសំរាប់ឱ្យខ្ញុំធ្វើ។ គាត់បានបង្រៀនខ្ញុំថា នៅពេលមានការហៅមកដល់ អ្នកទទួលយកវា ទោះជាអ្នកមានអារម្មណ៍ថាមិនសក្តិសមយ៉ាងណាក្តី។ ដូចជាម៉ូរ៉ូណៃបានធ្វើជាមួយនឹងយ៉ូសែប គាត់ត្រូវប្រាកដថា ខ្ញុំត្រូវបានរៀបចំជាស្រេច នៅពេលដល់ពេលឡើងនិយាយ។ គ្រូបង្រៀនដ៏បំផុសគំនិតនោះ បានជួយសង្គ្រោះជីវិតរបស់ខ្ញុំ។

នៅពេលខ្ញុំនៅជាយុវវ័យ បងប្រុស ភីធើរសិន ជាអ្នកត្រឡប់មកពីបេសកកម្មវិញថ្មីៗ បានបង្រៀនក្នុងថ្នាក់សាលា ថ្ងៃអាទិត្យរបស់យើង។ រៀងរាល់សប្តាហ៍ គាត់គូររូបព្រួញមួយដ៏ធំនៅលើក្តារខៀនគែមខាងក្រោម នៅឆ្វេងដៃ ចង្អុលទៅកាន់គែមខាងលើនៅខាងស្តាំដៃ។ បន្ទាប់មក គាត់នឹងសរសេរនៅលើក្តារខៀនថា "ដាក់គោលដៅឱ្យខ្ពស់"។

គោលលទ្ធិណាដែលគាត់បង្រៀន គាត់នឹងសុំឱ្យយើងពង្រីកសមត្ថភាពខ្លួន ឈោងទៅឱ្យកាន់តែខ្ពស់ជាងតាមដែលយើងគិតថាវាអាចធ្វើទៅបាន។ រូបព្រួញ និងពាក្យប៉ុន្មានម៉ាត់ថា *ដាក់គោលដៅឱ្យខ្ពស់* គឺជាការអញ្ជើញយ៉ាងខ្ជាប់ខ្ជួនក្នុងមេរៀនទាំងមូល។ បងប្រុស ភីធើរសិន បានធ្វើឱ្យខ្ញុំចង់បំរើបេសកកម្មដ៏ល្អមួយ ដើម្បីរៀនឱ្យកាន់តែពូកែនៅសាលារៀន ដើម្បីដាក់គោលដៅរបស់ខ្ញុំឱ្យខ្ពស់ជាងសំរាប់អាជីពរបស់ខ្ញុំ។

បងប្រុស ភីធើរសិន មានកិច្ចការមួយសំរាប់ឱ្យយើងធ្វើ។ គោលដៅរបស់គាត់បានជួយយើង "ឱ្យគិត ឱ្យទទួលអារម្មណ៍ ហើយបន្ទាប់មកធ្វើអ្វីមួយដើម្បីរស់នៅតាមគោលការណ៍ដំណឹងល្អទាំងឡាយ"។ ការបង្រៀនរបស់គាត់ បានជួយសង្គ្រោះជីវិតរបស់ខ្ញុំ។

នៅអាយុ 19 ឆ្នាំ ខ្ញុំត្រូវបានហៅឱ្យបំរើបេសកកម្មនៅកោះតាហ៊ីទី ជាកន្លែងដែលខ្ញុំត្រូវរៀនភាសាបរទេស ចំនួនពីរគឺ --- ភាសាបារាំង និងភាសាជនជាតិតាហ៊ីទី។ ពេលដំបូងក្នុងបេសកកម្មរបស់ខ្ញុំ ខ្ញុំបានបាក់ទឹកចិត្តណាស់ ដោយសារខ្ញុំមិនមានការរីកចំរើននៅក្នុងភាសាណាមួយទេ។ រាល់ពេល ខ្ញុំបានព្យាយាមនិយាយភាសាបារាំង មនុស្សបានឆ្លើយតបជាភាសាតាហ៊ីទី។ នៅពេលខ្ញុំបានព្យាយាមនិយាយភាសាតាហ៊ីទី ពួកគេបានឆ្លើយជាភាសាបារាំង។ ខ្ញុំហៀបនឹងចុះចាញ់ទៅហើយ។

បន្ទាប់មកនៅថ្ងៃមួយ នៅពេលខ្ញុំដើរកាត់បន្ទប់បោកខោអាវនៅផ្ទះបេសកកម្ម ខ្ញុំបានឮសម្លេងហៅខ្ញុំ។ ខ្ញុំបានងាកមើលជុំវិញ ហើយបានឃើញស្ត្រីជនជាតិតាហ៊ីទីសក់ស្កូវម្នាក់ កំពុងតែឈរនៅមាត់ទ្វារបោយដៃ ហៅខ្ញុំឱ្យត្រឡប់ទៅវិញ។ ឈ្មោះរបស់គាត់គឺទុពុតេអាតា មូ។ គាត់និយាយតែភាសាតាហ៊ីទីទេ។ ហើយខ្ញុំបាននិយាយតែភាសាអង់គ្លេសទេ។ ខ្ញុំចាប់មិនបាននូវអ្វីជាច្រើន ដែលគាត់ព្យាយាមប្រាប់ខ្ញុំទេ ប៉ុន្តែខ្ញុំបានយល់ថា គាត់ចង់ឱ្យខ្ញុំមកបន្ទប់បោកខោអាវជារៀងរាល់ថ្ងៃ ដើម្បីគាត់អាចជួយខ្ញុំរៀនភាសាតាហ៊ីទី។

ខ្ញុំបានឈប់នៅទីនោះប្រចាំថ្ងៃ ដើម្បីហាត់និយាយជាមួយគាត់ ខណៈពេលគាត់កំពុងអ៊ុតខោអាវ។ ពីដំបូង ខ្ញុំងឿងឆ្ងល់ថា តើការជួបរបស់យើងនឹងជួយអ្វីខ្លះទៅហ្ន៎! ប៉ុន្តែយូរៗទៅ ខ្ញុំបានចាប់ផ្ដើមយល់គាត់។ រាល់ពេលដែលយើងបានជួបគ្នា គាត់បានទំនាក់ទំនងមកកាន់ខ្ញុំដោយមានទំនុកចិត្តទាំងស្រុងថា ខ្ញុំអាចរៀនចេះភាសាទាំងពីរនេះ។

ស៊ិសស្ទើរ មូ បានជួយខ្ញុំរៀនភាសាតាហ៊ីទី។ ប៉ុន្តែគាត់បានជួយខ្ញុំរៀនច្រើនជាងនោះទៅទៀត។ គាត់កំពុងតែបង្រៀនខ្ញុំអំពីគោលការណ៍ទីមួយនៃដំណឹងល្អយ៉ាងពិតគឺ--- ឱ្យមានសេចក្ដីជំនឿទៅលើព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ។ គាត់បានបង្រៀនខ្ញុំថា បើសិនជាខ្ញុំទុកចិត្តលើព្រះអម្ចាស់ នោះទ្រង់នឹងជួយខ្ញុំឱ្យធ្វើនូវអ្វីដែលខ្ញុំគិតថា ខ្ញុំមិនអាចធ្វើទៅបាននោះ។ គាត់មិនមែនត្រឹមតែបានជួយសង្គ្រោះបេសកកម្មរបស់ខ្ញុំទេ--- តែគាត់បានជួយសង្គ្រោះជីវិតរបស់ខ្ញុំ។

ស៊ិសស្ទើរ ស្ទិលមិន បងប្រុស ភីធើរសិន និងស៊ិស្ទើរ មូ បានបង្រៀន "ដោយការលួងលោម ដោយការអត់ធ្មត់ ដោយការទន់ភ្លន់ និងការស្លូតបូត និងដោយការស្រឡាញ់ស្មោះត្រង់ ដោយចិត្តល្អ និងដោយការចេះដឹងដ៏បរិសុទ្ធ ដែលនឹងពង្រីកព្រលឹងឱ្យធំទូលំទូលាយ" (គ. និង ស. 121:41--42)។ ពួកគេបានបង្រៀនដោយមានគុណធម៌តុបតែងគំនិតរបស់ពួកគាត់ ហើយដោយសារតែហេតុនោះ ព្រះវិញ្ញាណបរិសុទ្ធគឺ ជាដៃគូដ៏ខ្ជាប់ខ្ជួនរបស់ពួកគាត់ (សូមមើល គ. និង ស. 121:45--46)។

គ្រូបង្រៀនដ៏អស្ចារ្យទាំងនេះ បានបំផុសគំនិតរបស់ខ្ញុំឱ្យសួរសំណួរជាច្រើនអំពីការបង្រៀនផ្ទាល់ខ្លួនរបស់ខ្ញុំថា:

1. ក្នុងនាមជាគ្រូបង្រៀន តើខ្ញុំមើលឃើញថាខ្លួនខ្ញុំជាសារទូតមកពីព្រះដែរឬទេ?
2. តើខ្ញុំរៀបចំខ្លួន រួចហើយបង្រៀនតាមរបៀបដែលអាចជួយសង្គ្រោះដល់ជីវិតទាំងឡាយដែរឬទេ?
3. តើខ្ញុំបានផ្ដោតទៅលើគោលលទ្ធិសំខាន់នៃការស្ដារឡើងវិញឬទេ?
4. តើអ្នកទាំងឡាយដែលខ្ញុំបង្រៀនទទួលអារម្មណ៍សេចក្ដីស្រឡាញ់ ដែលខ្ញុំមានចំពោះពួកគេ និងព្រះវរបិតាសួគ៌ និងព្រះអង្គសង្គ្រោះរបស់ខ្ញុំឬទេ?
5. នៅពេលមានការបំផុសគំនិត តើខ្ញុំបិទសៀវភៅ ហើយបើកភ្នែក បើកត្រចៀក និងបើកដួងចិត្តរបស់ពួកគេឱ្យមើលឃើញសិរីល្អរបស់ព្រះដែរឬទេ?
6. តើខ្ញុំបានអញ្ជើញឱ្យពួកគេធ្វើកិច្ចការដែលព្រះមានសំរាប់ពួកគេដែរឬទេ?
7. តើខ្ញុំបង្ហាញទំនុកចិត្តយ៉ាងខ្លាំងទៅលើពួកគេ ដែលពួកគេពិបាកនឹងបដិសេធការអញ្ជើញរបស់ខ្ញុំ ដែរឬទេ?
8. តើខ្ញុំបានជួយពួកគេឱ្យស្គាល់ពរជ័យដែលបានសន្យាថានឹងកើតមាន តាមការរស់នៅតាមគោលលទ្ធិដែលខ្ញុំកំពុងបង្រៀនដែរឬទេ?

ការរៀនសូត្រ និងការបង្រៀន មិនមែនជាសកម្មភាពដែលមានជំរើសនៅក្នុងនគររបស់ព្រះនោះទេ។ ការរៀនសូត្រ និងការបង្រៀនគឺមានអត្ថន័យខ្លាំងណាស់ ដែលដំណឹងល្អត្រូវបានស្ដារឡើងវិញនៅលើផែនដី ហើយដែលយើងនឹងទទួលបានជីវិតដ៏អស់កល្បជានិច្ច។ ការរៀនសូត្រ និងការបង្រៀនផ្ដល់ជាផ្លូវនាំឱ្យមានទីបន្ទាល់ផ្ទាល់ខ្លួន។ គ្មានផ្លូវទេ សំរាប់ឱ្យមនុស្សបាន "សង្គ្រោះក្នុងការល្ងង់ខ្លៅ" នោះ (គ. និង ស. 131:6)។

ខ្ញុំដឹងថា ព្រះមានព្រះជន្មរស់។ ខ្ញុំថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ។ ខ្ញុំធ្វើជាសាក្សីថា ព្យាការីយ៉ូសែប បានបើកគ្រាកាន់កាប់ត្រួតត្រានេះ តាមរយៈការរៀនពីសេចក្ដីពិត បន្ទាប់មកបង្រៀនសេចក្ដីពិត។ យ៉ូសែប បានសួរសំណួរមួយហើយមួយទៀត លោកបានទទួលចម្លើយដ៏ទេវភាព បន្ទាប់មកបានបង្រៀននូវអ្វីដែលលោកបានរៀន ទៅកាន់កូនចៅរបស់ព្រះ។ ខ្ញុំដឹងថាប្រធាន ម៉នសុន គឺជាអ្នកនាំពាក្យរបស់ព្រះអម្ចាស់នៅលើផែនដីសព្វថ្ងៃនេះ ហើយថា លោកបន្តរៀនសូត្រ និងបង្រៀនដល់យើងដូចជា យ៉ូសែប បានធ្វើ ពីព្រោះការបង្រៀនជួយសង្គ្រោះដល់ជីវិតមនុស្ស។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។